# មេរៀនទី ១២២ ៖ ព្រះយេស៊ូវប្រាប់អំពីសាសន៍សាម៉ារីចិត្តល្អ

## លូកា ១០៖២៥-៣៧

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/mE3alBdO5io

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/xpx-U4iTfQo

**គោលបំណង៖** ព្រះឲ្យតម្លៃចំពោះសេចក្តីមេត្តាករុណា។

**ខគម្ពីរចងចាំ៖** ម៉ាថាយ២២៖៣៩ *"ហើយបញ្ញត្តទី២ក៏បែបដូចគ្នា គឺថា «ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង»។"*

**ចំរៀង** ( *យូធូបលីង* )៖

១.កូនតូចៗអើយ https://youtu.be/ewu6Tfpo5Vo

២.ក្តីសប្បុរសទ្រង់ https://youtu.be/3Dvd4xrD_TI

៣. ខ្ញុំឱ្យបញ្ញត្តិមួយថ្មី https://youtu.be/lio2oGzBFz8

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ប្រណាំងគ្នាពាក់អាវ»




សម្ភារៈដែលត្រូវការ៖ អាវពីរដែលមានឡេវច្រើន

១. ចែកកុមារជាពីរក្រុម ហើយជ្រើសរើសកុមារ ២នាក់មកពីក្រុមនីមួយៗ

២. នៅពេលដែលគ្រូនិយាយថា ១ ២ ៣ កុមារម្នាក់ត្រូវពាក់អាវ ហើយម្នាក់ទៀតត្រូវព្យាយាមជួយបិតឡេវអាវនោះឲ្យបានលឿនតាមដែលអាចធ្វើបាន ពួកគេមានពេល ១នាទីក្នុងការលេង។ ក្រុមណាដែលអាចបិតឡេវអាវបានត្រឹមត្រូវនឹងលឿនជាងគេ នោះគេនឹងឈ្នះ ល្បែងនេះ។

៣. បន្តលេងល្បែងនេះ ដោយឲ្យកុមារផ្សេងជាអ្នកលេងម្តង។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះតែងតែចង់ឲ្យយើងចេះជួយអ្នកដទៃ និងបង្ហាញសេចក្តីសប្បុរស ពីព្រោះព្រះតែងតែបង្ហាញសេចក្តីសប្បុរសសម្រាប់យើងរាល់គ្នា។

### ៤. ការណែនាំមេរៀន

តើអ្នកជិតខាងរបស់អ្នកគឺជានរណា? គឺជាអ្នកដែលរស់នៅជិតជិតជាមួយអ្នកឬ? ឬក៏ជាអ្នកដែលចិត្តល្អជាមួយអ្នក? ឬក៏ជាអ្នកដែលតែងតែខ្វល់ពីអ្នក? ថ្ងៃនេះ ព្រះយេស៊ូវនឹងឆ្លើយសំណួរដែលទាក់ទងទៅនឹងបុរសសាសន៍សាម៉ារីចិត្តល្អម្នាក់!

### ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយមានអ្នកប្រាជ្ញច្បាប់ម្នាក់ដែលជាជនជាតិយូដា បានសួរទៅព្រះយេស៊ូវថា តើត្រូវឲ្យគាត់ធ្វើដូចម្តេចដើម្បីឲ្យបានជីវិតអស់កល្បជានិច្ចបាន។ ដូច្នេះព្រះយេស៊ូវក៏បានសួរគាត់ថា ក្នុងក្រឹត្យវិន័យ តើមានកត់ទុកយ៉ាងដូចម្តេច។ នៅក្នុងព្រះគម្ពីរ **លូកា ១០៖២៧** បានចែងថា "អ្នកនោះទូលថា «ឯងត្រូវស្រឡាញ់

ព្រះ អម្ចាស់ជាព្រះនៃឯង ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីកំឡាំង ហើយអស់អំពីគំនិតឯងព្រម ទាំង អ្នកជិតខាង ដូចខ្លួនឯងដែរ»  នោះគឺជាចម្លើយដ៏ល្អ ដូច្នេះព្រះយេស៊ូវក៏បានប្រាប់ឲ្យគាត់ធ្វើតាម ក្រឹត្យវិន័យនោះទៅ។

បន្ទាប់មកអ្នកប្រាជ្ញខាងច្បាប់នោះបានសួរថា "តើនរណាជាអ្នកជិតខាងរបស់ខ្ញុំ?" ដើម្បីឆ្លើយសំណួរ នេះ ព្រះយេស៊ូវបាននិយាយរឿងមួយ។

ព្រះយេស៊ូវមានព្រះបន្ទូលថា មានមនុស្សម្នាក់កំពុងតែធ្វើដំណើរពី ក្រុងយេរូសាឡិម ចុះទៅឯក្រុងយេរីខូរ គឺមានចម្ងាយប្រហែល ២៧គីឡូម៉ែត។ នេះជាផ្លូវដ៏គ្រោះថ្នាក់មួយ ដែលសម្បូរទៅដោយចោរប្លន់ជាច្រើន ហើយបុរសម្នាក់នេះត្រូវបានគេវាយប្រហារ ប្លន់ ហើយទុកឲ្យដេកស្លាប់នៅលើផ្លូវ។

បន្ទាប់មកគឺមានសង្ឃមួយអង្គ សង្ឃគឺដូចជាគ្រូគង្វាលអីចឹង ក៏បានដើរនៅលើផ្លូវជាមួយគ្នានោះ នោះពេលដែលគាត់បានឃើញបុរសម្នាក់កំពុងតែមានរបួស ហើយដេកស្តូកស្តឹងនៅលើផ្លូវ។ ប៉ុន្តែ គាត់មិនបានជួយអ្វីនោះទេ ហើយក៏ដើរចេញទៅ។ ពេលនោះ មានជនជាតិលេវីម្នាក់ ដែលមិនមែនជា សង្ឃ តែជាអ្នកជួយដល់សង្ឃ ដើរមកឃើញបុរសដែលដេកដូចស្លាប់។ តែគាត់ក៏ដើរចេញដោយមិនបាន ជួយគាត់សោះ!

នៅចុងបញ្ចប់បុរសដែលជាសាសន៍សាម៉ារីម្នាក់បានដើរឆ្លងកាត់ទីនោះ ហើយក៏បានឃើញបុរស ដែល មានរបួសនិងដេកដួលនៅទីនោះ។ ពួកយូដាគឺមិនឲ្យតម្លៃដល់ពួកសាសន៍សាម៉ារីនោះទេ។ ប៉ុន្តែ បុរសសាសន៍សាម៉ារីម្នាក់នេះមិនត្រឹមតែបានរុំរបួសរបស់បុរសនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានយក គាត់ទៅផ្ទះសំណាក់មួយ ហើយចេញថ្លៃចំណាយទាំងអស់។ គាត់ថែមទាំងសន្យាថានឹងបង់ប្រាក់បន្ថែម លើថ្លៃផ្ទះសំណាក់ដើម្បីមើលថែបុរសនេះទៀតផង!

ព្រះយេស៊ូវបានប្រាប់រឿងនេះដើម្បីពន្យល់ថា អ្នកជិតខាងជាមនុស្សដែលបង្ហាញចិត្តអាណិតអាសូរដល់ អ្នកឯទៀត។ ការអាណិតអាសូរគឺសំខាន់ចំពោះព្រះ ពីព្រោះព្រះមានចិត្តមេត្តា។ ពេលខ្លះយើងងាយភ្លេច ធ្វើចិត្តសប្បុរសនិងមេត្តាចំពោះអ្នកដទៃ។ ប្រហែលជាយើងរវល់ ឬប្រហែលជាយើងមិនខ្វល់ពីពួកគេ។ ប៉ុន្តែព្រះជាសេចក្តីស្រឡាញ់ ហើយទ្រង់ចង់ឲ្យយើងទាំងអស់គ្នាធ្វើជាអ្នកជិតខាងដ៏ល្អចំពោះមនុស្សជុំវិញ យើង ដោយបង្ហាញចិត្តអាណិតអាសូរដល់ពួកគេដូចជាសាសន៍សាម៉ារីដ៏ល្អម្នាក់។

## ៦. សំនួរពិភាក្សា

១. តើមានរឿងអ្វីកើតឡើងចំពោះបុរសម្នាក់ដែលបានធ្វើដំណើរពីយេរូសាឡិម ទៅយេរីខូរ?
*( ត្រូវចោរប្លន់ ហើយវាយទុកឲ្យដេកស្លាប់នៅតាមផ្លូវ)*

២. តើអ្នកគិតថាហេតុអ្វីបានជាសង្ឃ និងសាសន៍លេវីមិនជួយបុរសដែលមានរបួសនោះ?
*(ប្រហែលគេរវល់ ប្រហែលគេគិតថាគាត់ស្លាប់ហើយ ប្រហែលជាមិនចង់ប៉ះសាកសពទេ ប្រហែលជាមិនខ្វល់)*

៣. តើអ្នកគិតថា សង្ឃនិងសាសន៍លេវីបានធ្វើរឿងដ៏ត្រឹមត្រូវដែរឬទេ?(ទេ! គឺយើងត្រូវតែជួយគ្រប់ពេល)

៤. តើនរណាខ្លះដែលអ្នកគួរបង្ហាញចិត្តអាណិតអាសូរចំពោះគេ? *(គ្រួសារ មិត្តភក្តិ អ្នកជិតខាង។ល។)*

៥. តើអ្នកអាចបង្ហាញចិត្តអាណិតអាសូរ និងសេចក្តីសប្បុរសដល់ពួកគេបានដោយរបៀបណា?
*( ទុកឲ្យកុមារជាអ្នកឆ្លើយ)*




## ៧. ល្បែងកំសាន្ត «កុំប៉ះដី»

១. ចែកកុមារជាពីរក្រុមស្មើគ្នា

២. ក្រុមនីមួយៗត្រូវជ្រើសរើសគ្នា៤នាក់មក

៣. នៅពេលដែលគ្រូហៅលេខ នោះមានន័យថាមានជើង តែចំនួនប៉ុនណ្ណោះដែលអាចប៉ះ ដីបាន។




ឧទាហរណ៍៖ ប្រសិនបើគ្រូនិយាយថា ៤ នោះ មានន័យថាកុមារទាំង៤ នាក់ ត្រូវលើកជើងឡើងម្ខាង ឡើងលើ ដើម្បីឲ្យមានជើង តែ៤ប៉ុនណ្ណោះប៉ះដី។ ប្រសិន បើគ្រូនិយាយថា ៣ នោះគឺមានតែ ជើង ៣ប៉ុនណ្ណោះដែលអាចប៉ះដីបាន។

៤. ប្រសិនបើក្រុមណា មានជើងលើសឬខ្វះប៉ះដី នោះក្រុមគេនឹងចាញ់ល្បែងនេះ។ ក្រុមណាដែលអាចធ្វើបាននឹងទទួល បានពិន្ទុ។

៥. បន្តលេងល្បែងនេះនេះរហូតដល់កុមារទាំងអស់បានលេង គ្រប់ៗគ្នា

៦ បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថាពួកគេអាច បង្ហាញនូវសេចក្ដីសប្បុរសទៅកាន់អ្នកជទៃនូវគ្រប់កាលៈទេសៈទាំងអស់នៅក្នុងជីវិតរបស់ពួកគេ។ ព្រះតែងតែបង្ហាញនូវសេចក្ដីមេត្តាករុណារបស់ទ្រង់ចំពោះពួកយើង ដូច្នេះយើងត្រូវបង្ហាញនូវ សេចក្ដីមេត្តាករុណានិងជួយដល់អ្នកដទៃផងដែរ។

## ៨. ខគម្ពីរចងចាំ

**ម៉ាថាយ២២៖៣៩** *"ហើយបញ្ញត្តទី២ក៏បែបដូចគ្នា គឺថា «ត្រូវឲ្យស្រឡាញ់អ្នកជិតខាង ដូចខ្លួនឯង»។"*

## ៩. ហត្ថកម្ម «ខ្ញុំស្រលាញ់អ្នកជិតខាងខ្ញុំ»

សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម កូលេរ កន្ត្រៃ ខ្មៅដៃ និងការបិត



១. ព្រីនក្រដាសហត្ថកម្មហើយឲ្យទៅកុមារគ្រប់ៗគ្នា

២. ឲ្យកុមារផាត់ពណ៌និងតុបតែងវា

៣. ឲ្យកុមារសរសេរសេចក្ដីសប្បុរសអ្វីមួយក៏បាន នៅក្នុងរូបបេះដូងនោះ អំពីនរណាម្នាក់ក៏បានដែលគេចង់ប្រគល់បេះដូងនោះទៅឲ្យ។

៤. កាត់រូបបេះដូង និងរូបកាបូបនោះចេញមក។



៥. ប្រើការបិតផ្នែកចំហៀងកាបូបនោះទាំងសងខាង។

៦. ដាក់រូបបេះដូងចូលក្នុងកាបូបនោះ

៧. ឲ្យកុមារប្រគល់វាទៅឲ្យកុមារណោម្នាក់ក៏បានដែលពួកគេចង់បង្ហាញ ការអាណិតអាសូរដល់កុមារម្នាក់នោះ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

ពួកយើងទាំងអស់គ្នាគឺមានបាប ហើយប្រសិនបើគ្មានព្រះយេស៊ូវជួយលាងសម្អាតអំពើបាបរបស់យើងទេនោះ យើងទាំងអស់គ្នានិងពេញដោយអំពើបាបនិងគ្មានសង្ឃឹមទល់តែសោះ។ ប៉ុន្ដែប្រសើរជាងសាសន៍សាម៉ារីចិត្តល្អ ព្រះយេស៊ូវបានបង្ហាញយើងនូវសេចក្ដីសប្បុរស ដែលបានផ្លាស់ប្ដូរជីវិតរបស់យើងជារៀងរហូត។ សូមគិតអំពីរបៀបដែលព្រះបានបង្ហាញសេចក្ដីមេត្តាករុណានៅក្នុងជីវិតរបស់អ្នក។ តើបទពិសោធន៍ទាំងនោះបានប៉ះពាល់ដល់អ្នកយ៉ាងដូចម្ដេច? ព្រះចង់សង្គ្រោះយើងតាមរយៈការបូជានៃព្រះរាជបុត្រារបស់ទ្រង់ ប៉ុន្ដែទ្រង់ក៏ចង់ឱ្យយើងបង្ហាញការសប្បុរសដល់អ្នកដទៃ ដោយសារយើងបានសង្គ្រោះ។ សូមពិចារណាពីវិធីមួយចំនួនដែលអ្នកអាចក្លាយជាអ្នកជិតខាងដ៏ល្អម្នាក់ដោយការប្រាស្រ័យទាក់ទងនឹងសេចក្ដីស្រឡាញ់របស់ព្រះតាមរយៈសកម្មភាពរបស់អ្នក។


ខ្ញុំស្រឡាញ់អ្នកជិតខាងខ្ញុំ

